# បណអប់រំទី

## ស្តីអំពី: "គោរម្យជារនៃឧកាញ៉ា"

"រូបំ ជីរតិ មច្ចានំ, នាមគោត្តំ ន ជីរតិ" នេះ ជាពុទ្ធភាសិត ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់លើកតម្កើងសរសើរចំពោះកេរ្តិ៍ឈ្មោះកិត្តិយស នៃរាល់សព្វសត្វទាំងអស់ ដែលបានសាងនូវគុណតម្លៃទុកដល់អ្នកជំនាន់ក្រោយ ។ អត្ថន័យនៃពុទ្ធភាសិតនេះ មានសេចក្តីថា "រូបរាងកាយនៃគ្រប់មនុស្សសត្វ (ទាំងអស់ក្នុងលោកនេះ) តែងតែជរាគ្រាំគ្រាទ្រុឌទ្រោមទៅជាធម្មតា, មានតែកេរ្តិ៍ឈ្មោះវង្សត្រកូលទេដែលមិនជរាគ្រាំគ្រាស្លាប់បាត់បង់ទៅ" ។ ព្រោះហេតុតែកេរ្តិ៍ឈ្មោះមានគុណតម្លៃនៅរស់ជានិច្ច និងឆ្លុះបង្ហាញជនានុជនឲ្យស្គាល់ពីគុណធម៌ គុណសម្បត្តិ

ស្នាដៃ ចរិយាមារយាទរួមទាំងមុខមាត់សេចក្ដីថ្លៃថ្នូរ បែបនេះហើយ ទើបសង្គមទាំងមូលក្នុងផ្ទៃរាបនៃអន្តរជាតិ នាំគ្នាបញ្ញត្តឬបង្កើតតែងតាំងជាគោរម្យ-ងារផ្សេងៗ ដូចយ៉ាងពាក្យថា "សម្ដេច, ឯកឧត្ដម, **ឧកញ៉ានិងជំទាវ**" ជាដើម ដើម្បីជាគ្រឿងលើកទឹកចិត្តនិងបំពេញយសបន្ថែមទៅលើសកម្មភាពទុំៈទៅទៀត ។

នៅបណ្ដាប្រទេសផ្សេងៗលើសកលលោក ពុំសូវមានគោរម្យងារច្រើនជាន់គ្នា គណនាមិនបានដូចនៅប្រទេសខ្មែរយើងឡើយ ។ នៅប្រទេសខ្មែរមានគោរម្យងារច្រើនណាស់ សម្រាប់លើកកិត្តិយសបុគ្គល ទោះខាងវិស័យពុទ្ធចក្រក្ដី ទោះវិស័យខាងអាណាចក្រក្ដី ហើយដែលរឹតតែពេញនិយមណាស់ទៅទៀតនោះគឺពាក្យថា "**ឧកញ៉ា**" នេះតែម្ដង ។

មិនជាការខុសឆ្គងអ្វីទេ បុព្វបុរសខ្មែរយើង

ខិតខំបង្កើតបញ្ញត្តគោរម្យងារនេះឡើង ដើម្បីផ្ទាក់រចនាសម្គាល់បុគ្គលដែលបានបំពេញតួនាទី ឬពលិកម្មណាមួយយ៉ាងពិសេស ចំពោះសង្គមចំពោះជាតិមាតុភូមិខ្លួន ហើយអ្នកនោះបរិបូណ៌ដោយគុណធម៌ថែមទៀត ។ ជាក់ស្តែង ពីសម័យបុរាណខ្មែរយើង មានវីរបុរសអ្នកស្នេហាជាតិច្រើនរូបដែរ ដូចជា ឧកញ៉ាក្រឡាហោមគង់ ឧកញ៉ាឃ្លាំងមឿង និងឧកញ៉ា សឺន គុយ ចៅហ្វាយខេត្តព្រះត្រពាំង ដែលអាផ្សាធរយួនចាប់យកទៅសម្លាប់ចោលជាដើម




សុទ្ធសឹងតែជាអ្នកស្នេហាជាតិ តស៊ូដើម្បីជាតិ ស្រឡាញ់ប្រយោជន៍ជាតិ មិនទាមទារអ្វីពីសង្គម

ជាតិខ្លួនឡើយ ហើយរហូតហ៊ានទៅដល់លះបង់ជីវិតបូជាចំពោះជាតិទៀត, នេះទើបត្រូវទទួលតំណែងគោរម្យងារជាឧកញ៉ា ដោយភាពពេញលេញ ។

ផ្ទុយពីសម័យបុរាណ ក្នុងសម័យបច្ចុប្បន្ននេះ គោរម្យងារជាឧកញ៉ានេះ ហាក់ដូចជាងាយនឹងទទួលបានណាស់ក្នុងប្រទេសខ្មែរយើង មានលក់ពេញទឹកពេញដីពេញប្រទេស រាល់អាកាំម៉ាស់ដឹកមិនអស់ឡើយ ពីព្រោះមានចែងក្នុងព្រះរាជក្រឹត្យឲ្យតែអស់លោកណាមានថវិកាចំនួន ១០០.០០០ ដុល្លារ ក៏អាចទិញបានគោរម្យងារនេះមកទុកក្នុងខ្លួន គ្រាន់សម្ដែញឲ្យគេកោតខ្លាចបានហើយ មិនលំបាកបញ្ចេញវីរភាព ទៅតស៊ូនាំខ្លួនឲ្យវេទនាប៉ុន្មានឡើយ ។ គឺអ៊ីចឹងហើយ ទើបប្រទេសខ្មែរយើងសម័យនេះ សម្បូណ៌អ្នកមានគោរម្យងារជាឧកញ៉ា

ច្រើនមែនទែន គួរណាស់តែប្រទេសសម្បូណ៌សប្បាយ ជីវភាពរាស្ត្រធូរធារ ប្រទេសមានស្ថេរភាពនិងរីកចម្រើនហើយ មិនគួរប្រទេសជាតិខ្លួនមកបាត់បង់ធនធានធម្មជាតិ បាត់បង់ដែនទឹកដែនគោកដែនកោះ ជួនកាលទៅប្ដូរយកដីពីរាស្ត្រក្រីក្ររហាមឲ្យកាន់តែដុនដាបថែមទៀតនោះទេ ។ ក្រែងមកពីយ៉ាងនេះទេដឹង ការខិតខំប្រឹងប្រែងស្រវាយកគោរម្យងារនេះ ដើម្បីទុកជាផ្លូវសម្រាប់ប្រកបអំពើទុច្ចរិត អំពើកេងប្រវញ្ចន៍ អំពើពុករលួយ ស្រូបយកផលប្រយោជន៍ សេដ្ឋកិច្ចលើខ្នងរាស្ត្រហើយមើលទៅ? បើពុំដូច្នេះទេ ខ្លួនពុំមានគុណសម្បត្តិអ្វីជាដុំកំភួនសោះ ម្ដេចក៏ប្រាថ្នាការស្រេកឃ្លានពីគោរម្យ-ងារនេះខ្លាំងម្ល៉េះ ។ នាបច្ចុប្បន្ននេះ អស់លោកខ្លះជាឧកញ៉ាដែរតែជាអ្នកបំផ្លាញសម្បត្តិធនធានធម្មជាតិ, អស់លោកខ្លះជាឧកញ៉ាដែរ ហើយមានទ្រព្យសម្បត្តិ

មហាសាល តែជាអ្នកប្លន់ដីពីប្រជាពលរដ្ឋ, អស់លោកខ្លះទៀតនោះជាឧកញ៉ាដែរ តែជាអ្នកឃោរឃៅដើរគំរាមកំហែង ប្រព្រឹត្តអំពើអយុត្តិធម៌ក្នុងសង្គមថា បើប្រព្រឹត្តអំពើអយុត្តិធម៌ហើយ ក៏សុំឲ្យទុកជីវិតមនុស្សឲ្យបានរស់នៅទៅចុះ បែរជាមិនអស់ចិត្តទេ ធ្លៀតទៅបញ្ឆាកញ្ជះរបស់ខ្លួនឲ្យកេះកៃកាំភ្លើង បាញ់សម្លាប់មនុស្សល្អទៀត ដូចករណីឧកញ៉ា **ថោង សារ៉ាត់** កម្ចាត់ឧកញ៉ា **អ៊ឹង ម៉េងជី** កាលពីយប់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៤ ជាដើម ។



អានទិន៍ស្តាប់មើលទៅឃើញថា អស់លោកទាំងនោះ មានគោរម្យងាររជាឧកញ៉ាក៏ពិតមែន តែគ្មានភាពជាឧកញ៉ាសោះទេ បានសេចក្តីថា អស់លោកទាំងនោះ មិនមានគុណធម៌សុជីវធម៌ ឧត្តមគតិ គុណវុឌ្ឍិឲ្យសក្តិសមនឹងគោរម្យងាររនោះឡើយ ព្រោះមុខមាត់ជាឧកញ៉ានេះ ជាអ្នកមានសីលធម៌ខ្ពស់ណាស់ ហើយប្រកបគុណធម៌ឧត្តមគតិស្នេហាជាតិ មានវីរភាពអង់អាចមិនហ៊ានលើកដៃបៀតបៀនអ្នកណាឡើយ ។

ខុសស្រឡះពីបុរាណកាល ដែលឧកញ៉ាកាលនោះជាអ្នកហ៊ានពលិកម្មជីវិត តស៊ូដើម្បីបុព្វហេតុជាតិ ជាវីរបុរសពុះពារលំបាកតោកយ៉ាកល្ងាចព្រឹក បានបាយខ្វះទឹកដេកផុបដេកព្រៃជិះតែដំរីសេះរទេះឈើ ទប់ទល់សម្លាប់ខ្មាំងសត្រូវមិនឲ្យចូលមកឈ្លានពាន ទន្ទ្រានដែនអាណាចក្រខ្លួនបាន

ឡើយ មានពេលខ្លះត្រូវបក្សពួកខ្លាំងតិរច្ឆានសាមន្យ ចាប់យកទៅសម្លាប់ចោលទៀតផង ឯអស់លោកឧកញ៉ាសម័យនេះ មិនចេះក្សាច់គុនអ្វីមួយស្មៀតផង មិនបានចេញទៅទីសង្គ្រាមមួយជំហានសោះ ដេកសុទ្ធតែកូមិគ្រឹះរចនាដោយក្បូរក្បាច់យ៉ាងស្រស់ប្រិមប្រិយ បរិភោគសុទ្ធតែអាហារល្អប្រណីតឈ្ងុយឆ្ងាញ់ពិសា មានទាំងទាសាទាសីអាមីអាថោងព្រោងព្រាត ចាំបម្រើឆ្វេងស្តាំ អញ្ជើញទៅណាមកណាសុទ្ធតែរថយន្តពិសេសទំនើបៗ មានអង្គរក្សសម្រាប់ការពារខ្លួនទៀតផង,យើងមិនឃើញបង្ហាញនូវវីរភាពដើម្បីបូរណភាពជាតិអ្វីសោះ ក៏ស្រាប់តែឡើងលោតផ្លោះទៅដល់គោរម្យងារ ជាឧកញ៉ាដោយគ្រាន់តែបោះលុយ ចំនួន១០ទៅ១៥ម៉ឺនដុល្លារប៉ុណ្ណោះ ។ បានយសប៉ុណ្ណឹង ដោយមិនបានបញ្ចេញញើសឈាមការពារជាតិហើយ ក៏សុំឲ្យអស់

ចិត្តទៅចុះ តែនៅមិនស្កប់ទេ អស់លោកខ្លះទៀតទៅបំផ្លាញសម្បត្តិជាតិក៏មាន អស់លោកខ្លះទៀតទៅលក់ជាតិឲ្យគេក៏មាន អស់លោកខ្លះទៀតទៅដណ្តើមគំរាមពក់លួចហ៊ុមព័ទ្ធយកដីស្រែ ពីរាស្ត្រតូចតាចក៏មាន ដល់ទៅប្រជារាស្ត្រអស់ដីអស់សម្បត្តិនឹងឲ្យលួចយកបានទៀត ម្តងនេះក៏បង្វែរមហិច្ឆតាខ្លួន តម្រង់កាណុង រកបុគ្គលដែលមានវណ្ណៈដូចគ្នាវិញម្តង ដើម្បីបានការឈ្នះការអស់ចិត្ត ធ្វើឲ្យព្រឹត្តិការណ៍នេះផ្អើលគឹកកង នៅកណ្តាលទីក្រុង ហើយត្រូវអាប់ឱនកិត្តិយសដល់អស់លោក ដែលមានគោរម្យងារបែបនេះដែរ ។

នេះជាព្រឹត្តិការណ៍ពិត ដែលបានកំពុងកើតឡើងក្នុងសង្គមយើង ។ ការដែលខំបញ្ញត្តបង្កើតនូវគោរម្យងារជាច្រើន ដើម្បីបំពាក់យសមុខមាត់ នៃឥស្សរជនណាម្នាក់នោះ ជាការប្រសើរណាស់ទៅ

ហើយ តែការបាក់មុខមាត់នៃសង្គម វិបត្តិនៃសង្គម ភាពអយុត្តិធម៌នៃសង្គម និទ្ទណ្ឌភាពនៃសង្គម ចេះកើតមានឡើង ក៏ព្រោះតែការបញ្ញត្តបង្កើតនូវគោ-រម្យងារឋានន្តរៈ ដែលច្រើនហួសហេតុពេកនេះដែរ៕

អធិប្បាយបន្ថែមដោយឧបាសកសាចារ្យ លី ប៊ុនលីង

**អត្ថបទសម្រង់ពីទស្សនវិភាគខ្លី**

របស់លោកគ្រូព្រះមហាជម្ពាលង្ការ ចាន់ សុជន

ប្រធានកម្មវិធីជាជីសំឡេងព្រះធម៌

វត្តប្រាសាទស្រះកណ្ដាល(ខ្វាស់)

ចានពិនិត្យ និង ឯកភាព

ធ្វើនៅវត្តប្រាសាទស្រះកណ្ដាល(ខ្វាស់)

ថ្ងៃ ៨រោច ខែមិគសិរ ព.ស.២៥៥៨

ត្រូវនឹងថ្ងៃអាទិត្យ ទី១៤ ខែធ្នូ ឆ្នាំ២០១៤